ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ ១៧៤/១១ អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១

# របាយការណ៍

## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ តុលា ឆ្នាំ ២០១១
## និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែ វិច្ឆិកា ឆ្នាំ ២០១១

(ពីថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១១ ដល់ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យក្នុងការត្រួតពិនិត្យគ្រឿងញៀន ដើម្បីចូលរួមចំណែកអនុវត្ត "គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុងខែតុលា ឆ្នាំ ២០១១ នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែតុលានេះ ក្រុមឈ្មួញគ្រឿងញៀនក្នុងតំបន់ នៅតែបន្តនាំគ្រឿងញៀនសំយោគប្រភេទ មេតំហ្វេតាមីនគ្រាប់ (WY) និង មេតំហ្វេតាមីនទឹកកក (ICE) ចូលមកក្នុងប្រទេសតាមបណ្តាច្រកនៃតំបន់ព្រំដែននៅភាគឦសាន ជាពិសេសគឺតាមច្រករបៀងនានា ដើម្បីផ្គត់ផ្គង់ទីផ្សារនៅក្នុងស្រុកមួយចំនួន និងមួយចំនួននាំបន្តទៅក្រៅប្រទេស ។ ដោយឡែក ឧក្រិដ្ឋជនគ្រឿងញៀន កោះតៃវ៉ាន់ បានធ្វើសកម្មភាពនាំគ្រឿងញៀនប្រភេទ អ៊ិចស្តាស៊ី តាមរូបភាពលាក់នៅក្នុងកញ្ចប់បញ្ញើគ្រឿងកុំព្យូទ័រ ហើយផ្ញើតាមក្រុមហ៊ុនសេវាកម្មដឹកជញ្ជូនរហ័ស ចេញពីទីក្រុងហុងកុង ចូលមកកម្ពុជាតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលត្រូវបានសមត្ថកិច្ចគយ-រដ្ឋាករកម្ពុជា មន្ត្រីនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សហការជាមួយមន្ទីរប្រឆាំងគ្រឿងញៀន រកឃើញនិងឃាត់ខ្លួនចំនួន ២ នាក់ ។ ជាមួយគ្នានេះ នៅរាជធានី-ខេត្តក្នុងប្រទេស អនុវត្តតាម"គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព" បានបន្តកិច្ចប្រតិបត្តិការបង្រ្កាបបទល្មើសជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀន ដែលកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនយ៉ាងសកម្ម សំដៅចូលរួមចំណែកការពារពិធីខួបទី២០នៃការយាងនិវត្តន៍មកកាន់មាតុប្រទេសរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រជាតិខ្មែរ, ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មថ្វាយព្រះអង្គគម្រប់ ៨៩ យាង ចូល ៩០ ព្រះវស្សា, ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា, ទិវាកំណើតកងយោធពលខេមរភូមិន្ទ និងបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ខែតុលានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវការណែនាំ និងវិធានការជាគោលនានា សម្រាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ :

- សារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ផ្ញើជូនលោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស មាតាបិតា អាណាព្យាបាលសិស្ស នាឱកាសបើកបវេសនកាលឆ្នាំសិក្សា ២០១១-២០១២ "ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១" ។
- សេចក្តីសម្រេច របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែន កម្ពុជា-ឡាវ (សេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១) ។

ដោយឡែក ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការដឹកនាំ និង ណែនាំឱ្យអនុវត្តយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន (ខ្លឹមសារដឹកនាំនិងណែនាំមាននៅក្នុងឧបសម្ព័ន្ធ) ។ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំខាងលើ អាជ្ញាធរជាតិបានខិតខំអនុវត្តទទួលលទ្ធផលដូចខាងក្រោម :

### ១. *ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

- ឯកឧត្តម **កៅ ខុនជាវ៉ា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអញ្ជើញជាអធិបតីនៅក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សា ២០១១-២០១២ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១១ នៅវិទ្យាល័យឥន្ទ្រទេវី ។
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ, ក្រសួង-ស្ថាប័ននានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានបន្តយកចិត្តទុកដាក់លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង គ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈសកម្មភាពដូចខាងក្រោម :

#### ១.១. *សកម្មភាពអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ រួមមាន :*

- ក្រសួងមហាផ្ទៃ តាមរយៈកម្មវិធីសន្តិសុខមាតុភូមិ បានបន្តការផ្សព្វផ្សាយ ស្ព័ត អប់រំបង្ការការប្រើប្រាស់គ្រឿងញៀន តាមកម្មវិធីប្រចាំថ្ងៃរបស់ស្ថានីយទូរទស្សន៍នានា និងអនុញ្ញាតឱ្យតំណាងអគ្គស្នងការដ្ឋាននគរបាលជាតិចូលរួមផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន រយៈពេល ៩ខែ ឆ្នាំ២០១១ របស់ក្រសួងមហាផ្ទៃ (២៦/១០/២០១១) ។
- ក្រសួងព័ត៌មាន បានបន្តជំរុញក្រុមសិល្បករ ពិធីករ តន្ត្រីករ តាមបណ្តាស្ថានីយវិទ្យុ-ទូរទស្សន៍រដ្ឋ និងឯកជន ឱ្យបង្កើនសកម្មភាពផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។
- ក្រសួងកិច្ចការនារី បានបន្តជំរុញការផ្សព្វផ្សាយអប់រំ ស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសារសំខាន់៧ពាក់ពន្ធ័នឹងការបង្ការទប់ស្កាត់គ្រឿងញៀន តាមវិទ្យុនិងទូរទស្សន៍ ។
- ក្រសួងធម្មការនិងសាសនា បានបន្តការអនុវត្តកម្មវិធីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម ដើម្បីលើកកម្ពស់សីលធម៌រស់នៅល្អក្នុងសង្គម ចៀសផុតពីការប្រើប្រាស់គ្រឿងញៀន និងអំពើហិង្សា ។
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានបន្តណែនាំដល់ផលិតកម្មភាពយន្ត-វីដេអូ និងក្រុមហ៊ុន នាំចូល នាំចេញ ខ្សែ

ភាពយន្ត-វីដេអូ ឱ្យដាក់ **សារ** អប់រំពីគ្រឿងញៀន នៅលើផលិតផលនៃផលិតកម្មរបស់ខ្លួន ។

- ក្រសួងទេសចរណ៍ បានបន្តចាក់ផ្សាយ Spot "កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ" ជាភាសាខ្មែរ-ភាសាបរទេស តាមទូរទស្សន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅតាមទូរទស្សន៍បរទេស រួមទាំងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយ ដ្ឋានស្អាត សេវាកម្មល្អ" ដោយមានរំលេចសារអប់រំពីបញ្ហាគ្រឿងញៀន ។

### ១.២. *សកម្មភាពផ្សព្វផ្សាយអប់រំផ្ទាល់តាមសហគមន៍ជាតិ* *រួមមាន :*

- ក្រសួងទេសចរណ៍ បាននិងកំពុងជំរុញឱ្យមន្ទីរទេសចរណ៍ រាជធានី-ខេត្ត អនុវត្តតាមស្មារតីអនុក្រឹត្យស្តីពី មគ្គុទ្ទេសក៍ទេសចរណ៍ ។
  - បានជំរុញមន្ទីរទេសចរណ៍រាជធានី-ខេត្ត ឱ្យបិទផ្សាយនូវបណ្ណ័ផ្សព្វផ្សាយអំពីគ្រឿងញៀន អេដស៍ ការជួញដូរមនុស្ស និងការជួញដូរអាវុធជាតិផ្ទុះ នៅតាមគោលដៅសេវាកម្មទេសចរណ៍ (ផ្ទះសំណាក់, សណ្ឋាគារ កន្លែងកម្សាន្ត នានា) ។
  - បានជំរុញមន្ទីរទេសចរណ៍រាជធានី-ខេត្ត សហការជាមួយសមាគមសណ្ឋាគារ សេវាស្នាក់នៅទេសចរណ៍ សមាគមដឹកជញ្ជូនទេសចរណ៍ សេវាក្លឹបកម្សាន្តទេសចរណ៍ ម៉ាស្សា ខារ៉ាអូខេ ដើម្បីចុះផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀនទៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ និងតាមរយៈការបញ្ច្រាបយេនឌ័រ នៅខេត្តតំបន់ឆ្នេរសមុទ្រ រួមមាន ខេត្តព្រះសីហនុ កោះកុង កំពត កែប ដល់ប្រតិបត្តិករទេសចរណ៍ និងបុគ្គលិកបម្រើសេវាកម្មទេសចរណ៍ ។
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងពាណិជ្ជកម្ម បានបន្តជំរុញវិស័យឯកជនអនុវត្តការបិទសារអប់រំ ពីផលប៉ះពាល់នៃគ្រឿងញៀននៅលើផលិតផលភេសជ្ជៈ ម្ហូបអាហារ និងផលិតផលផ្សេងៗរបស់ក្រុមហ៊ុនខ្លួន ។
- ក្រសួងសាធារណការនិងដឹកជញ្ជូន បានបន្តសហការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក (មាត្រា ៧៥ ពាក់ពន្ធ័នឹងការធ្វើតេស្តជាតិអាកុលនិងគ្រឿងញៀន) និងបន្តអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងការប្រកបអាជីវកម្មផ្លូវថ្នល់ (មាត្រា ១២ ពាក់ពន្ធ័នឹងការហាមឃាត់ការដឹកជញ្ជូនទំនិញមានគ្រោះថ្នាក់ ទំនិញមានក្លិនអាក្រក់ ទំនិញដែលរដ្ឋហាមឃាត់ ដូចជា គ្រឿងញៀន ជាដើម) ។

សកម្មភាពផ្សព្វផ្សាយអប់រំដោយផ្ទាល់នៅតាមសហគមន៍ របស់ក្រសួង-ស្ថាប័នដែលមានការពាក់ពន្ធ័ រួមទាំងសកម្មភាពអប់រំផ្សព្វផ្សាយជាប្រចាំ របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ១៤ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន (ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ) មានអ្នកចូលរួមសរុបចំនួន ***៣៩.៣៩០*** នាក់ ។

## ២. *ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន*

ខែតុលានេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រក្នុងការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

### ២.១. *ការបង្ក្រាបបទល្មើសគ្រឿងញៀន*

**-បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៤៦** ករណីលើ ៥០ ករណី ប្រៀបធៀបខែកញ្ញា ឆ្នាំ២០១១ គឺថយចុះ **៨** % ។

**-ជនសង្ស័យ** ឃាត់ខ្លួន ចំនួន **១០២** នាក់ លើ ១៣៥ នាក់ ប្រៀបធៀបខែកញ្ញាឆ្នាំ២០១១ គឺថយចុះ ២៤ % ។

ក្នុងនោះ មាន ជនជាតិ ខ្មែរ ៩០ នាក់ ( ស្រី ១៦ នាក់ ), វៀតណាម ៩ នាក់ ( ស្រី ៤ នាក់ ), ឡាវ ១ នាក់ ( ប្រុស ), តៃវ៉ាន់ ២ នាក់ ( ប្រុស ) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

**-វត្ថុតាងគ្រឿងញៀន** រួមមាន :

មេតំហ្វេតាមីនគ្រាប់ WY ២.៨៧៩ ½ គ្រាប់, មេតំហ្វេតាមីនទឹកកក(Ice) ៥២៣,៦៤ ក្រាម, ម្សៅមេតំហ្វេតាមីន ៦៥៤,៦ ក្រាម, អ៊ិចស្តាស៊ី ៥.២២៧ គ្រាប់ និង ១.០៤៥,៨ ក្រាម, ហេរ៉ូអ៊ីន ២០,០៧ ក្រាម, កេតាមីន ២,៦៣ ក្រាម, កញ្ឆាក្រៀម ១៣០ ក្រាម ត្រូវបានចាប់យក ។

**-ទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន** រួមមាន :

ប្រាក់ ៦៤៧.១០០ រៀល, ១៤.៧៤៩ ដុល្លារអាមេរិក, ៦.៥០០.០០០ ដុង, រថយន្ត ៣ គ្រឿង, ម៉ូតូ ៨ គ្រឿង រួមទាំងវត្ថុតាងមួយចំនួនទៀត ( មានរាយនៅក្នុងឧបសម្ព័ន្ធ ) ត្រូវបានចាប់យក ។

### ២.២. ការធ្វើកោសល្យវិច័យលើសំណាកវត្ថុតាង

**មន្ទីរពិសោធន៍គ្រឿងញៀន** របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងក្នុងខែតុលានេះ បានចំនួន ៥០ សំណាក ក្នុង ៣៨ករណី ក្នុងនោះ សំណាក **អវិជ្ជមានសារធាតុញៀន** មាន **១ សំណាក = ១ %** និងសំណាក **វិជ្ជមានសារធាតុញៀន ៤៩ សំណាក = ៩៩ %** គឺ ៖

| | |
|---|---|
| -មេតំហ្វេតាមីនទឹកកក (Ice) ២៧ សំណាក = ៥៥,១០ % | -មេតំហ្វេតាមីនគ្រាប់ ១៦ សំណាក = ៣២,៦៥ % |
| -ជ័រកញ្ឆា ១ សំណាក = ២ % | -កេតាមីន ២ សំណាក = ៤,០៨ % |
| -ហេរ៉ូអ៊ីន ២ សំណាក = ៤,០៨ % | -សាហ្វ្រូល ១ សំណាក = ២ % |

### ២.៣. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ

សារធាតុគីមីផ្សំដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) នៅក្នុងខែតុលា នេះ សរុបមានចំនួន **១.១១១.៨៤០** គ.ក្រ ( មានរាយមុខសារធាតុគីមីក្នុងតារាងឧបសម្ព័ន្ធ ) ។

## ៣. ការព្យាបាល / ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

### ៣.១. ការងារព្យាបាល / ស្តារនីតិសម្បទា

ខែតុលានេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តសហការជាមួយក្រសួងពាក់ព័ន្ធលើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្តោតសំខាន់ទៅលើ ការការរៀបចំផែនការសកម្មភាព ផែនការថវិកា គោលនយោបាយ គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីបំពេញឱ្យការងារព្យាបាល/ស្តារនីតិសម្បទា និងកាត់បន្ថយគ្រោះថ្នាក់ ជាអាទិ៍ :

- ការដាក់បញ្ចូលផែនការអភិវឌ្ឍន៍សេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន របស់ក្រសួងសុខាភិបាល ទៅក្នុងផែនការជាតិ ៥ ឆ្នាំ លើកទី២ ( ២០១១-២០១៥ ) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន របស់ អ.ជ.ប.គ.ញ ។
- ការស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យលទ្ធភាពបញ្ចូលថវិកា សម្រាប់អនុវត្តផែនការអភិវឌ្ឍន៍សេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ទៅក្នុងសេចក្តីព្រាងផែនការថវិកាជាតិ ឆ្នាំ២០១២ ។

- ប្រកាស ស្តីពីការបង្កើតគណៈកម្មាធិការដើម្បីកសាង និង អភិវឌ្ឍមជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (លេខ ២២៨៤ ស.អ.យ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ។

*៣.២. ការកាត់បន្ថយគ្រោះថ្នាក់*

**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣** បាន :

- ដឹកនាំកិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោងស្តីពីកម្មវិធីអេដស៍សម្រាប់តំបន់អាស៊ី ប្រចាំនៅកម្ពុជា (គម្រោង HAARP) ដើម្បីដោះស្រាយលើចំណុចមិនសមហេតុផលមួយចំនួនក្នុងបទបង្ហាញស្តីពីឧបសគ្គនានាក្នុងការអនុវត្តគម្រោង HAARP នៅកម្ពុជា និងពិភាក្សាលើការងារបច្ចេកទេសមួយចំនួន ដែលបានឯកភាពគ្នានៅក្នុងកិច្ចប្រជុំថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១ (កិច្ចប្រជុំត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោងស្តីពីកម្មវិធីអេដស៍សម្រាប់តំបន់អាស៊ី ប្រចាំនៅកម្ពុជា) ។
- ចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ចូលរួមក្នុងសិក្ខាសាលាស្តីពីការពិគ្រោះយោបល់ទៅលើការបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិ ស្តីពីយន្តការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅកម្ពុជា (១៤/១០/២០១១) ។
- ក្រុមការងារជាតិស្តីពី គ្រឿងញៀន/អេដស៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានព្រាងផែនការយុទ្ធសាស្ត្រជាតិក្នុងការឆ្លើយតបចំពោះការប្រើបំពានគ្រឿងញៀន និងការឆ្លងរាលដាលមេរោគអេដស៍/ជំងឺអេដស៍ ឆ្នាំ២០១១-២០១៥ ដោយបានដាក់ឆ្លងកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ជាមួយដៃគូពាក់ពន្ធ័ ដូចជាតំណាងស្ថាប័នអង្គការសហប្រជាជាតិ តំណាងអង្គការសង្គមស៊ីវិលក្នុងស្រុក តំណាងស្ថាប័នជាតិផ្សេងៗ និងអ្នកជំនាញពាក់ពន្ធ័ ។
- បានចាត់មន្ត្រីជំនាញ ដើម្បីធ្វើការសិក្សាវាយតម្លៃលើការអនុវត្តកម្មវិធីម្តុល/ស៊ីរ៉ាំងនៅកម្ពុជា ។ តាមការពិនិត្យលើខ្លឹមសារទូទៅជារួមគឺរបាយការណ៍ បានបង្ហាញពីហេតុផលវិជ្ជមានមួយចំនួន សម្រាប់ជាត្រីវិស័យក្នុងការអនុវត្តកម្មវិធីនេះនៅពេលខាងមុខ ។
- តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចាត់តាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន១រូប ទៅចូលរួមកិច្ចប្រជុំការងាររួមរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍អំពីការងារមេរោគអេដស៍/ជំងឺអេដស៍ ។ អង្គប្រជុំបានបង្ហាញនូវសូចនករតាមដានរួម, សូចនករនៃការទទួលបានសេវាជាសកល និងអាទិភាពអន្តរាគមន៍, របាយការណ៍របស់ក្រុមការងារបច្ចេកទេសយុទ្ធសាស្ត្រទី១(បង្ការ) និងបញ្ហាផ្សេងៗរួមមាន : ផែនទីបង្ហាញផ្លូវ, ការព្យាករណ៍អំពីការរាលដាលមេរោគអេដស៍ និងបច្ចុប្បន្នភាពស្តីពីមូលនិធិសកល ។

## *៤. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានសហការសម្របសម្រួលជាមួយអង្គការដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដើម្បីលើកកម្ពស់សមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ ជាអាទិ៍ :

- បានចូលរួមផ្តល់នូវបទឧទ្ទេសនាម ក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ជំនាន់ទី១៧ ឆ្នាំ២០១១ ដល់នាយទាហានរងនៃកងរាជអាវុធហត្ថ(នារី) ចំនួន១០០ នាក់ នៅសាលាកងរាជអាវុធហត្ថកំបូល ។
- បានបញ្ចប់បេសកកម្មត្រួតពិនិត្យ ដើម្បីត្រៀមរៀបចំ តួនាទី ភារកិច្ច សមាសភាព ទីតាំង សម្ភារៈ ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន ១៤ កន្លែង ដែលបានសហការបង្កើតឡើងតាំងពីឆ្នាំ២០០២ ដល់ ឆ្នាំ២០១១ ។ លទ្ធផលដែលបានមកពីការចុះត្រួតពិនិត្យជារួមគឺ សម្ភារៈរបស់ការិយាល័យមួយចំនួនចាស់ខូចគុណភាព, កិច្ចសហការរវាងសមាជិក BLO និងតាមបណ្តាខេត្តនៅមានការយល់ច្រឡំគ្នាអំពី តួនាទី និង ភារកិច្ច, ការយល់ ដឹង និង សមត្ថភាពជំនាញរបស់មន្ត្រីអនុវត្តច្បាប់នៅមានកម្រិត ។
- បានបញ្ចប់ការសិក្សាប្រមូលព័ត៌មានពាក់ពន្ធ័នឹងការចរាចរ និងប្រើប្រាស់សារធាតុគីមីផ្សំនៅក្នុងខេត្តកណ្តាល និង ខេត្តស្វាយរៀង ។ តាមរយៈ ការជួបសម្ភាសន៍ផ្ទាល់មាត់ និងបំពេញកម្រងសំណួរ ជាមួយមន្ត្រីរាជការ នៃមន្ទីរជំនាញដែលមានការពាក់ពន្ធ័ដូចជា មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរសុខាភិបាល មន្ទីរពាណិជ្ជកម្ម កងកម្លាំងប្រដាប់អាវុធ សាខាគយនិងរដ្ឋាករ មន្ត្រីនៅមូលដ្ឋាន និងប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់ដែលមានការប្រើប្រាស់សារធាតុគីមីផ្សំ ក្រុមការងារក្តាប់បានពីភាពអវិជ្ជមានមួយចំនួនដូចខាងក្រោម :
  - មន្ត្រីថ្នាក់គ្រប់គ្រង និងបុគ្គលិកជំនាញនៅតាមមន្ទីរជំនាញដែលមានការពាក់ពន្ធ័ ភាគច្រើនមិនបានដឹងថាអ្វីខ្លះដែលជាសារធាតុគីមីផ្សំគ្រឿងញៀននៅឡើយ ។
  - ខេត្តមិនទាន់មានយន្តការច្បាស់លាស់ណាមួយសម្រាប់ទទួលខុសត្រូវលើការគ្រប់គ្រង ការត្រួតពិនិត្យការចរាចរ ការប្រើប្រាស់សារធាតុគីមីផ្សំនៅឡើយ ។
  - ប្រជាពលរដ្ឋដែលរស់នៅក្បែរកន្លែងដែលមានប្រើសារធាតុគីមី ភាគច្រើនបានបង្ហាញពីផលប៉ះពាល់ ដូចជាការប៉ះពាល់ទៅលើសុខភាព(ជំងឺក្អក-រមាស់) និងផលប៉ះពាល់ទៅលើដំណាំផ្សេងៗ ។
- បានពិភាក្សាការងារបឋមជាមួយនាយកដ្ឋានឱសថ ចំណីអាហារនិងគ្រឿងសំអាងនៃក្រសួងសុខាភិបាល ក្នុងគោលបំណងពង្រឹងការងារគ្រប់គ្រងសារធាតុគីមីផ្សំ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល ។
- បានបញ្ចប់ការរៀបចំកែសម្រួលឯកសារកម្មវិធីបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន និងបានបញ្ជូនទៅក្រសួងអប់រំយុវជននិងកីឡា ដើម្បីសហការពិនិត្យនិងកែសម្រួលតាមបច្ចេកទេសគរុកោសល្យ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ទទួលបានលទ្ធផលដូចខាងក្រោម :

- បានដឹកនាំប្រតិភូអន្តរក្រសួងទៅចូលរួមក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន លើកទី៣២ ស្តីពីកិច្ចការគ្រឿងញៀន ASEAN Senior officials on Drug Matters. ASOD (ថ្ងៃទី ១០-១២/ ១០/២០១១) នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ ។ កិច្ចប្រជុំ ASOD លើកនេះ កម្ពុជាបានជួបពិភាក្សាការងារជាលក្ខណៈទ្វេភាគី មានដូចតទៅ :

- **កិច្ចពិភាក្សាទ្វេភាគី កម្ពុជា-ថៃ** : ភាគីថៃបានស្នើសុំឱ្យកម្ពុជារៀបចំកិច្ចប្រជុំទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន លើកទី៦ នៅខេត្តព្រះសីហនុ ពីថ្ងៃទី២៨ខែវិច្ឆិកា ដល់ថ្ងៃទី០១ខែធ្នូឆ្នាំ២០១១ ដោយមិនចាំបាច់មានការបែងចែកជាកិច្ចប្រជុំថ្នាក់មន្ត្រីប្រតិបត្តិ និងកិច្ចប្រជុំថ្នាក់មន្ត្រីគោលនយោបាយ ។
- **កិច្ចពិភាក្សាទ្វេភាគី កម្ពុជា-ឡាវ** : ភាគីឡាវនឹងផ្តល់សម្ភារៈផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់កម្ពុជានៅពេលប្រជុំត្រីភាគី/ទ្វេភាគី កម្ពុជា-វៀតណាម-ឡាវ នាថ្ងៃទី១៥-១៧ខែវិច្ឆិកាឆ្នាំ២០១១ ។ ដោយឡែក ការដាក់តាំងផ្ទាំងប៉ាណូអប់រំពីគ្រឿងញៀន ដែលបានឯកភាពគ្នាគឺ ខាងកម្ពុជានឹងដាក់តាំង១ផ្ទាំងនៅច្រកត្រពាំងគ្រាល (ខេត្តស្ទឹងត្រែង) ហើយខាងភាគីឡាវនឹងដាក់តាំង១ផ្ទាំង នៅច្រកកំពង់ស្រឡៅ (ខេត្តព្រះវិហារ) ។
- **កិច្ចពិភាក្សាទ្វេភាគី កម្ពុជា-វៀតណាម** : ឆ្នាំនេះ កម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះទទួលដំណើរទស្សនកិច្ច របស់គណៈប្រតិភូជាន់ខ្ពស់វៀតណាម ដោយកាលបរិច្ឆេទនឹងពិភាក្សាគ្នានៅពេលក្រោយ ។
- **កិច្ចពិភាក្សាទ្វេភាគី កម្ពុជា-ម៉ាឡេស៊ី** : ពាក់ពន្ធ័នឹងដំណើរទស្សនកិច្ច ឬវគ្គបណ្តុះបណ្តាលលើការងារ ព្យាបាលដោយផ្អែកលើសហគមន៍ ត្រូវបានភាគីម៉ាឡេស៊ីទទួលស្វាគមន៍ ។
- **កិច្ចពិភាក្សាទ្វេភាគី កម្ពុជា-UNODC** : អង្គការ UNODC នឹងផ្តល់កុំព្យូទ័រ(លទ្ធភាពអាចមានចំនួនប្រហែល១០គ្រឿង) ក្នុង១ប្រទេសដែលជាសមាជិកមហាអនុតំបន់ទន្លេមេគង្គ (កម្ពុជា វៀតណាម ឡាវ ថៃ ភូមា និង ចិន) តាមរយៈគម្រោង H15 (គម្រោងស្តីពីភាពជាដៃគូនៃបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គស្តីពីការត្រួតពិនិត្យគ្រឿងញៀន) ។ UNODC បានជូនដំណឹងដល់កម្ពុជាគឺនៅឆ្នាំ ២០១២ កម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ MOU ។

- បានចាត់មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ៣ រូប និងសម្របសម្រួលជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងសុខាភិបាល ក្នុងការចាត់បញ្ជូនមន្ត្រីជំនាញចំនួន ២ រូប ដើម្បីទៅចូលរួមក្នុងសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការប្រមូលទិន្នន័យ ការវិភាគ និងធ្វើរបាយការណ៍សម្រាប់គោលនយោបាយ និងសកម្មភាព កាលពីថ្ងៃទី១៨-២១/១០/២០១១ នៅ ទីក្រុងបាងកក ប្រទេសថៃ ។

ក្រៅពីការអនុវត្តសកម្មភាពពហុវិស័យខាងលើ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រពហុវិស័យទាំង ៥ មានដូចខាងក្រោម :

**១.** បានរៀបចំក្រុមការងារទៅចូលរួមប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀនជាមួយគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ នៃរដ្ឋសភា ។

**២.** បានចូលរួមក្នុងសិក្ខាសាលាអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០១១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣ ។

**៣.** បានបន្តការចុះសិក្សាបឋមនៅក្នុង រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ និង ខេត្តស្វាយរៀង ដើម្បីប៉ាន់ប្រមាណពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀន និងឥរិយាបថគ្រោះថ្នាក់របស់ពួកគេ ។

## III. ការសន្និដ្ឋាន និងវាយតម្លៃ

ក្នុងខែតុលានេះ ដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងកម្លាំងសរុបរបស់សង្គម យើងបានអនុវត្តយុទ្ធសាស្ត្រពហុវិស័យទាំង ៥ ក្នុងការត្រួតពិនិត្យគ្រឿងញៀន ទទួលបានលទ្ធផលល្អប្រសើរ ។ សមត្ថភាពក្នុងការអនុវត្តការងារ លើការងារផ្សព្វផ្សាយអប់រំ ការអនុវត្តច្បាប់ ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ត្រូវបានលើកកម្ពស់ជាបណ្តើរៗ ។ ក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់ត្រូវបានពង្រឹង ។ ប៉ុន្តែក៏ពិនិត្យឃើញនៅមានចំណុចខ្វះខាត និងបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ លើការងារកាត់បន្ថយតម្រូវការគ្រឿងញៀន ទាំងឯកសារ-សម្ភារៈ គឺយើងនៅតែប្រើប្រាស់ឧបករណ៍ សម្ភារៈចាស់ដដែលៗ មិនទាន់បានធ្វើបច្ចុប្បន្នភាពនៅឡើយ ។ ធនធានមនុស្សសម្រាប់បម្រើការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀនក៏នៅមិនទាន់មានគ្រប់គ្រាន់ ។ ចំពោះការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ជារួមទោះបីមន្ត្រីអនុវត្តច្បាប់នៅមូលដ្ឋានបានខិតខំយ៉ាងសកម្មក្នុងការបង្រ្កាបបទល្មើស ប៉ុន្តែការលក់រាយ និងការប្រើប្រាស់គ្រឿងញៀននៅតែមានសញ្ញាកត់សំគាល់នៅឡើយ ។ លើការងារព្យាបាលនិងស្តារនីតិសម្បទា យើងបានយកចិត្តទុកដាក់ពង្រឹងដល់មណ្ឌលបណ្តុះអាសន្ន អប់រំបន្សាប និងព្យាបាល ឱ្យមានដំណើរការបានល្អ និងកាន់តែបានសមស្របជាងមុន ប៉ុន្តែកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅតែមិនទាន់មានដំណើរការបានពេញលេញ ដើម្បីជួយសម្រាលបន្ទុកដល់មណ្ឌលទាំងអស់នោះបាននៅឡើយ ។ យើងបានបើកវគ្គបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីអនុវត្តជាបន្តបន្ទាប់ ប៉ុន្តែយើងនៅមិនទាន់បានចុះទៅបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់តាមខេត្តគោលដៅមួយចំនួន ជាពិសេស បណ្តាខេត្តនៅតាមតំបន់ព្រំដែន ដែលសមត្ថភាពមន្ត្រីនៅទីនោះ នៅមានកម្រិតនៅឡើយ ។ ដោយឡែក កិច្ចសហប្រតិបត្តិការអន្តរជាតិ ជារួមយើងបានខិតខំពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ បានច្រើនជាមួយបណ្តាប្រទេស និងអង្គការជាដៃគូអភិវឌ្ឍន៍ ប៉ុន្តែយើងមិនទាន់ទទួលបានអត្ថប្រយោជន៍ពេញលេញពីគម្រោងទាំងនោះមកវិញនៅឡើយ ។

## IV. ទិសដៅសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែវិច្ឆិកា ឆ្នាំ២០១១

ដើម្បីធ្វើឱ្យមាននិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តនូវទិសដៅសកម្មភាពមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. អគ្គលេខាធិការដ្ឋាន នឹងអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តស្ទឹងត្រែង ឬខេត្តសៀមរាប ដើម្បីផ្តល់កិច្ចសម្ភាសន៍ នៅស្ថានីយទូរទស្សន៍ CTN ក្រោមប្រធានបទស្តីពី សកម្មភាពនិងលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់ខេត្ត ។

១.២. ត្រៀមរៀបចំពិព័រណ៍រូបភាព សម្រាប់បុណ្យខួប ២០ ឆ្នាំ នៃការយាងនិវត្តន៍មកកាន់មាតុប្រទេស របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រជាតិខ្មែរ និង ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មថ្វាយព្រះអង្គគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា, ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា, ទិវាកំណើតកងយោធពលខេមរភូមិន្ទ និងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ។

១.៣. ត្រៀមរៀបចំផែនការសកម្មភាព សម្រាប់ការរៀបចំវេទិកាសំណួរ-ចម្លើយ សម្រាប់សិស្ស និស្សិតវិទ្យាល័យ និងមហាវិទ្យាល័យ ដើម្បីបង្កើនចំណេះដឹងពីបញ្ហាគ្រឿងញៀន តាមប្រពន្ធ័ផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ ។

១.៤. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ននានា សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រឿងញៀន តាមប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និង ឯកជន និងបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ននានា ក្នុងការចុះទៅបណ្តុះបណ្តាលផ្សព្វផ្សាយអប់រំផ្ទាល់នៅតាមសហគមន៍ជាតិ រួមទាំងបន្តជំរុញរាជធានី-ខេត្ត ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំជាប្រចាំ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គការ UNODC តាមរយៈគម្រោង PATROL ដើម្បីពិនិត្យលទ្ធភាពក្នុងការរៀបចំបង្កើតស្ថានីយសម្រាប់សម្ភាសន៍ទេសន្តរប្រវេសន៍នៅច្រកទ្វារអន្តរជាតិ**ចាំយាម**(ខេត្តកោះកុង) និងច្រកទ្វារអន្តរជាតិ**ប៉ោយប៉ែត** (ខេត្តបន្ទាយមានជ័យ) ។

២.២. បន្តកិច្ចសហការជាមួយអង្គការ UNODC ក្នុងការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែនសមុទ្រ (BLO) ។

២.៣. បន្តសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងយុត្តិធម៌ ដើម្បីជំរុញការអនុវត្តតាមនីតិវិធីច្បាប់ឱ្យមានប្រសិទ្ធិភាព ចំពោះករណីចាប់បានប្រេងម្រះព្រៅនៅខេត្តកំពង់ឆ្នាំង និងករណីចាប់បានប្រាក់ ២០៩.៩០០ ដុល្លារអាមេរិកនៅខេត្តស្ទឹងត្រែង ។

២.៤. បន្តកិច្ចសហការសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីរិះរកវិធានការទប់ស្កាត់ការប្រើប្រាស់និងចែកចាយគ្រឿងញៀននៅក្នុងពន្ធនាគារ ។

## ៣. ការងារព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

៣.១. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គម-កិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) ដើម្បីតាមដានសំណើសុំ ជំនួយសាងសង់មជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានដាក់ស្នើសុំទៅភាគីវៀតណាម តាមរយៈកិច្ចប្រជុំគណៈកម្មការចម្រុះទ្វេភាគី កម្ពុជា-វៀតណាម លើកទី១២ ។

៣.២. បន្តសហការសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានការអនុវត្តកម្មវិធីប្រចាំថ្ងៃនៅតាមមណ្ឌលបណ្តោះអាសន្នអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋនិងឯកជន ។

៣.៣. បន្តតាមដានការអនុវត្តផែនការអភិវឌ្ឍន៍សេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន របស់ក្រសួងសុខាភិបាល ។

៣.៤. ត្រៀមផ្សព្វផ្សាយបទពិសោធន៍លើការងារព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ នៅខេត្តកោះកុង ។

៣.៥. បន្តសហការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ដើម្បីជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តិនានា ពាក់ព័ន្ធនឹងការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## ៤. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

៤.១. បន្តកិច្ចសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តកំពង់ចាម ខេត្តតាកែវ និងខេត្តកំពត ដើម្បីធ្វើការសិក្សាប្រមូលព័ត៌មានពាក់ពន្ធ័នឹងការចរាចរ ការប្រើប្រាស់សារធាតុគីមី ។

៤.២. បន្តសហការសម្របសម្រួលជាមួយអង្គការដៃគូអភិវឌ្ឍន៍ គណៈកម្មាធិការត្រួតពិនិត្យខេត្ត ដែលមិនទាន់បានបណ្តុះបណ្តាល ដើម្បីបន្តបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់ ។

៤.៣. បន្តការរៀបចំកែសម្រួល តួនាទី ភារកិច្ច សមាសភាព របស់ការិយាល័យទំនាក់ ទំនងព្រំដែន (BLO) ទាំង ១៤ កន្លែង នៅតាមបណ្តោយព្រំដែន កម្ពុជា-ថៃ កម្ពុជា-វៀតណាម និង កម្ពុជា-ឡាវ ។

៤.៤. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន នៅខេត្តប៉ៃលិន និង ខេត្តបាត់ដំបង ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ត្រៀមទៅចូលរួមប្រជុំ Asia Pacific Gigh level Intergovernmental Meeting on the Assessment of Progress Against the Commitment in the Political Declaration on HIV/AIDS and the Millennium Development Goals (MDGs) នៅថ្ងៃទី០១-០៣ ខែវិច្ឆិកា ឆ្នាំ២០១១ នៅទីក្រុងបាងកក ប្រទេសថៃ ។

៥.២. ត្រៀមទៅចូលរួមសិក្ខាសាលាអន្តរជាតិ ស្តីពីការអភិវឌ្ឍដំណាំជំនួស នៅថ្ងៃទី០៦-១២/១១/២០១១ នៅទីក្រុងបាងកក ប្រទេសថៃ ។

៥.៣. ត្រៀមរៀបចំគណៈប្រតិភូទៅចូលរួមកិច្ចប្រជុំ ត្រីភាគី / ទ្វេភាគី លើកទី១១ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន (ថ្ងៃទី១៥-១៧ ខែវិច្ឆិកា ឆ្នាំ២០១១) ។

៥.៤. ត្រៀមទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលអ្នកស៊ើបអង្កេតអន្តរជាតិ ដែលនឹងត្រូវធ្វើនៅថ្ងៃទី៣១ ខែតុលា-១១ ខែវិច្ឆិកា ឆ្នាំ២០១១ នៅទីក្រុងឡាអេ ប្រទេសហូឡង់ ។

៥.៥. ត្រៀមសហការជាមួយអង្គការ UNODC ( គម្រោង PATROL) ដើម្បីរៀបចំកិច្ចប្រជុំលើកទី២ នៃគណៈកម្មាធិការអ្នកផ្តល់ប្រឹក្សា (C-PAC) គម្រោង PATROL នៅខេត្តកំពង់ចាម ថ្ងៃទី ២២-២៣ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៥.៦. ត្រៀមទៅចូលរួមសន្និសីទគ្រឿងស្រវឹង និងកិច្ចប្រជុំដៃគូអនុវត្តគម្រោង របស់វិទ្យាស្ថាន IOGT-NTO MOVEMENT របស់ប្រទេសស៊ុយអែត ធ្វើនៅទីក្រុងបាងកក ប្រទេសថៃ ថ្ងៃទី២៧ ខែវិច្ឆិកា-04 ខែធ្នូ ឆ្នាំ២០១១ ។

៥.៧. ត្រៀមលក្ខណៈរៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី៦ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងគ្រឿងញៀន (ធ្វើនៅខេត្តព្រះសីហនុ, ថ្ងៃទី២៨ ខែវិច្ឆិកា-០១ ខែធ្នូ ២០១១) ។

៥.៨. ត្រៀមទៅចូលរួមសន្និសីទស្តីពីគោលនយោបាយអាកុល សកល ឆ្នាំ២០១១ "ស្តីពីយុទ្ធសាស្ត្រអាកុលសកល ទៅជាសកម្មភាពថ្នាក់ជាតិ និងក្នុងស្រុក និង កិច្ចប្រជុំភាពជាដៃគូ SEA RO III នៅទីក្រុងបាងកក ប្រទេសថៃ ថ្ងៃទី២៨ វិច្ឆិកា-០៣ ធ្នូ ២០១១ ។

ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រពហុវិស័យទាំង ៥ ខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដូចជា :

- បន្តការតាមដាន និងជំរុញកិច្ចសហការជាមួយគណៈកម្មការជំនាញ នៃស្ថាបន័នីតិប្បញ្ញត្តិ ចំពោះសេចក្តីព្រាង ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ស្នើសុំការពិនិត្យ និងអនុម័ត ។
- បន្តជំរុញការរៀបចំផែនការជាតិ ៥ ឆ្នាំ (២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- ត្រៀមលក្ខណៈសម្បត្តិឱ្យបានឆាប់រហ័ស ក្នុងការរៀបចំដំណើរទស្សនកិច្ចសិក្សា អំពីប្រព័ន្ធទិន្នន័យព័ត៌មានគ្រឿងញៀន ដើម្បីជូនដំណឹងទៅស្ថានទូតប្រទេសសឹង្ហបុរី ប្រចាំនៅកម្ពុជា ។
- បន្តជំរុញការរៀបចំសាលាបៃតង ដើម្បីផ្សព្វផ្សាយ និងអនុវត្តនៅឆ្នាំ២០១២ ខាងមុខ ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន
-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ
"ដើម្បីជូនជ្រាប"
-ក្រសួង សមាជិក អជបគញ
-ក្រសួងផែនការ
-អគ្គលេខាធិការដ្ឋាន អជបគញ
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីមុខការ"
-ឯកសារ

*សកម្មភាពសំខាន់ៗក្នុងការដឹកនាំ*
*អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ខែ តុលា ឆ្នាំ២០១១*

| ល.រ | ខ្លឹមសារ និង គោលដៅ |
|---|---|
| ១ | ការណែនាំឲ្យរៀបចំក្រុមការងារចូលរួមប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ជាមួយគណៈកម្មការ |

| | |
|---|---|
| | មហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាតនិងមុខងារសាធារណៈ នៃរដ្ឋសភា (ចំណារឯកឧត្តមប្រធាន អ.ជ.ប.គ.ញ ថ្ងៃទី២៣/៩/២០១១) |
| ២ | ការណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រៀបចំសេចក្តីសម្រេចមួយ ដើម្បីរៀបចំសរសេរគម្រោងពាក់ពន្ធ័នឹងការអភិរក្ស និង អភិវឌ្ឍ នៅតំបន់ដែលមានដើមម្រះព្រៅភ្នំ (លិខិតលេខ ២១ ស.ណ.ន ចុះថ្ងៃទី២០/៩/២០១១ របស់ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន) |
| ៣ | ការណែនាំឲ្យបន្តសហការសម្របសម្រួលជាមួយស្នងការដ្ឋាននគរបាលជាតិ ក្រសួងយុត្តិធម៌ ចំពោះករណីប្រេងម្រះភ្នំ ដែលចាប់បាននៅខេត្ត កំពង់ឆ្នាំង (លិខិតលេខ ២១ ស.ណ.ន ចុះថ្ងៃទី២០/៩/២០១១ របស់ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន) |
| ៤ | កិច្ចប្រជុំជាមួយ គណៈកម្មាធិការសម្របសម្រួលមូលនិធិសកល ក្នុងការប្រឆាំងជំងឺអេដស៍ របេង និងគ្រុនចាញ់ នៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី១២/១០/២០១១ (លិខិតលេខ ២១ ស.ណ.ន ចុះថ្ងៃទី២០/៩/២០១១ របស់ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន) |
| ៥ | ការណែនាំឲ្យសហការជាមួយក្រសួងមហាផ្ទៃ អង្គការ UNODCគម្រោង PATROL ដើម្បីរៀបចំបង្កើតស្ថានីយសម្រាប់សម្ភាសន៍ទេសន្តរ ប្រវេសន៍ចំនួន ២ កន្លែង នៅច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត និង ចាំយាម(លិខិតលេខ ២១ ស.ណ.ន ចុះថ្ងៃទី២០/៩/២០១១ របស់ខុទ្ទ កាល័យ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន) |
| ៦ | ការណែនាំឲ្យជំរុញរៀបចំដំណើរទស្សនកិច្ចនៅប្រទេសសឹង្ហបុរី លើការងារទិន្នន័យព័ត៌មានគ្រឿងញៀន (លិខិតលេខ ២១ ស.ណ.ន ចុះថ្ងៃទី ២០/៩/២០១១ របស់ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន) |
| ៧ | បានណែនាំឲ្យចូលរួមពិធីបើកបវេសនកាលឆ្នាំសិក្សា ២០១១-២០១២ "ថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១១" នៅវិទ្យាល័យឥន្ទ្រទេវី (ដោយឯក-ឧតម កៅ ខុនដាក់ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន) |
| ៨ | ការណែនាំឲ្យគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន លើកទី៣២ នៅទីក្រុងវៀងចន្ទ័ ប្រទេសឡាវ ថ្ងៃទី ១០/១២-១០/ ២០១១ (ដឹកនាំដោយ ឯ.ឧ មាស វីរិទ្ធ) |
| ៩ | ការស្នើសុំឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់បញ្ចូលថវិកាបន្ថែមទៅក្នុងផែនការថវិកា របស់ក្រសួងសុខាភិបាលប្រចាំឆ្នាំ២០១២ សម្រាប់ ដំណើរការលើការងារព្យាបាលដោយផ្អែកលើសហគមន៍ |
| ១០ | ការស្នើសុំឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់បញ្ចូលថវិកាបន្ថែមទៅក្នុងផែនការថវិកា របស់ក្រសួងសុខាភិបាលប្រចាំឆ្នាំ២០១២ សម្រាប់ អនុវត្តផែនការអភិវឌ្ឍសេវាសុខភាពផ្លូវចិត្ត និង គ្រឿងញៀន |
| ១១ | បានណែនាំឲ្យដាក់បញ្ចូល ផែនការអភិវឌ្ឍសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ៥ឆ្នាំ របស់ក្រសួងសុខាភិបាល ទៅក្នុងផែនការយុទ្ធសាស្ត្រ ជាតិ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| ១២ | បានណែនាំឲ្យថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ចូលរួមកិច្ចប្រជុំការងាររួមរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ អំពីការងារមេរោគអេដស៍/ជំងឺ អេដស៍ (ថ្ងៃទី ១១/១០/២០១១) |
| ១៣ | បានណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រៀបចំកិច្ចប្រជុំត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការដឹកនាំគម្រោង ស្តីពីកម្មវិធីអេដស៍សម្រាប់ តំបន់អាស៊ី ប្រចាំនៅកម្ពុជា (គម្រោង HAARP) ថ្ងៃទី២០ /១០/២០១១ |
| ១៤ | បានណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រៀមលក្ខណៈចូលរួមប្រជុំ ត្រីភាគី / ទ្វេភាគី កម្ពុជា វៀតណាម ឡាវ លើកទី១១ ស្តីពីកិច្ច សហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន (ថ្ងៃទី១៥-១៧ វិច្ឆិកា ឆ្នាំ២០១១ នៅប្រទេសឡាវ) |

## សកម្មភាពផ្សព្វផ្សាយអប់រំ ប្រចាំខែ តុលា ឆ្នាំ២០១១

| ល.រ | ឈ្មោះស្ថាប័ន | ខ្លឹមសារផ្សព្វផ្សាយ | អ្នកចូលរួម |
|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ | -បានចូលរួមធ្វើបទឧទ្ទេសនាម ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងយុទ្ធសាស្ត្រក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ជំនាន់ទី១៧ ឆ្នាំ២០១១ ដល់សិក្ខាកាមជានាយទាហានរង នៃកងរាជអាវុធ(នារី) នៅសាលាកងរាជអាវុធហត្ថ(កំបូល) ចំនួន ១០០ នាក់ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១<br>-បានចាត់មន្ត្រីជំនាញ ដើម្បីចុះទៅពិនិត្យជាក់ស្តែងនៅក្នុងតំបន់ដែលអង្គការ កសាង ធ្លាប់បានអនុវត្តកម្មវិធីប្តូរម្ជុល/ស៊ីរាំង នៅក្នុងសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ (ར.ប.ក របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ លេខ ៣៥៦.១១ អ.ជ.ប.គ.ញ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១)<br>-បានអញ្ជើញឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធី ស៊ី.ធី.អិន អ៊ីនធឺណេត ស្តីពីសកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់ខេត្តស្ទឹងត្រែង (២៦ខែតុលា ឆ្នាំ២០១១ | ១០០ នាក់ |
| ២ | ក្រចេះ | -អាជ្ញាធរក្រុងក្រចេះ បានចុះផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ចំនួន ៥ លើក មានអ្នកចូលរួម **១៥៩** នាក់ (ស្រី៥៨នាក់) | ១៥៩ នាក់ |
| ៣ | ព្រះវិហារ | -អាជ្ញាធរស្រុកចំនួន ៧ និងក្រុងចំនួន១ ផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន សរុបចំនួន៨៧លើក | ២៧.៣៧៨ |

| | | | |
|---|---|---|---|
| | | ដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស សរុបចំនួន ២៧.៣៧៨ / ស្រី ១៤.៥៥៨ នាក់ ( តួលេខខែតុលា របស់ខេត្ត ) | នាក់ |
| ៤ | កំពង់ធំ | -អាជ្ញាធរស្រុកប្រាសាទបល្ល័ង្គ បានចុះផ្សព្វផ្សាយច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន បានចំនួន ៤ លើក ដល់ប្រជាពលរដ្ឋ **១.៤៣០** នាក់ / ស្រី ៩៦៧ នាក់<br>-ស្នងការដ្ឋាននគរបាលខេត្ត បានចុះផ្សព្វផ្សាយច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀនបានចំនួន ៣ លើក តាមកន្លែងខារ៉ាអូខេ មានអ្នកចូលរួម **៩១** នាក់ / ស្រី ៧៨ នាក់ | ១.៥២១ នាក់ |
| ៥ | ឧត្តរមានជ័យ | -អធិការដ្ឋានស្រុកចុងកាល់ ផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន ១ លើក = **២៧** នាក់ | ២៧ នាក់ |
| ៦ | តាកែវ | -ស្នងការដ្ឋាននគរបាលខេត្ត បានចុះបិទផ្សាយបម្រាម ហាមប្រើប្រាស់គ្រឿងញៀនបានចំនួន២៥ ផ្ទះសំណាក់ និង ២៩ កន្លែងខារ៉ាអូខេ | |
| ៧ | ស្វាយរៀង | -អាជ្ញាធរខេត្ត ផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន ចំនួន ១៤ លើក = **១.៦១០** នាក់( ស្រី ២២៨នាក់ ) | ១.៦១០ នាក់ |
| ៨ | ព្រៃវែង | -ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយ វរសេនាធំការពារព្រំដែនខេត្តដុងថាប វៀតណាម ផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅស្រុកពាមជរ ១ លើក មានអ្នកចូលរួម **២៥០** នាក់ | ២៥០ នាក់ |
| ៩ | បាត់ដំបង | -ផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅស្រុកថ្មគោល ១៣ លើក = **៤.៨៦៥** នាក់ / ស្រី ២.០៩៥ នាក់, នៅស្រុកសំពៅលូន ១ លើក = **១២** នាក់ / ស្រី ៣ នាក់ ( ស្រង់ពី រ.ប.ក ខែតុលា របស់ខេត្ត ) | ៤.៨៧៧ នាក់ |
| ១០ | កំពង់ឆ្នាំង | -ស្នងការដ្ឋាននគរបាលខេត្ត ផ្សព្វផ្សាយផលប៉ះពាល់នៃគ្រឿងញៀន ច្បាប់ចរាចរណ៍ ១លើក មានលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សក្នុងវិទ្យាល័យក្រុងកំពង់ឆ្នាំងចូលរួម **១.៨៨៧** ( ស្រី ៨១១ នាក់ ) | ១.៨៨៧នាក់ |
| ១១ | កំពង់ស្ពឺ | -ស្នងការដ្ឋាននគរបាលខេត្ត ផ្សព្វផ្សាយច្បាប់ ត្រួតពិនិត្យគ្រឿងញៀន នៅស្រុកភ្នំស្រួច ឃុំត្រែងត្រយឹង ដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស ចំនួន៤ ភូមិ = **៣៧៦** នាក់( ស្រី ១៤២ នាក់ ) និងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលចំនួន ៤ ប៉ុស្តិ៍ = **២៩** នាក់ | ៤០៥ នាក់ |
| ១២ | កែប | -អធិការដ្ឋាននគរបាលក្រុងកែប និង ស្រុកដំណាក់ចង្អើរ ផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន ចំនួន ៤ លើក មានអ្នកចូលរួម **២៨០** នាក់( ស្រី ១១៤ នាក់ )<br>-អាជ្ញាធរក្រុងកែប ស្រុកដំណាក់ចង្អើ ផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន ចំនួន ៤ លើក = **៣៤៧** នាក់( ស្រី ២១៩ នាក់ ) | ៦២៧ នាក់ |
| ១៣ | ប៉ៃលិន | -ក្រុងប៉ៃលិន សហការជាមួយអង្គការ **ជេឌ** ផ្សព្វផ្សាយផលប៉ះពាល់នៃគ្រឿងញៀនមានអ្នកចូលរួម **៦៧** នាក់ | ៦៧ នាក់ |
| ១៤ | កំពង់ចាម | -ផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន នៅស្រុកចំការលើ មានអ្នកចូលរួម **១៩៣** នាក់ / ស្រី ៦៣ នាក់ ( ដកស្រង់ចេញពី រ ប ក ខែតុលា របស់ខេត្ត ) | ១៩៣ នាក់ |
| ១៥ | កំពត | -ផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន នៅក្នុង ៣ ស្រុក និង ១ ក្រុង មានអ្នកចូលរួម **២៨៩** នាក់ / ស្រី ១៧៨ នាក់ ( ស្រង់ចេញពី រ ប ក ខែតុលា របស់ខេត្ត ) | ២៨៩ នាក់ |
| សរុប | | | **៣៩.៣៩០ នាក់** |

## បទល្មើសគ្រឿងញៀនដែលបង្ក្រាប ក្នុងខែ តុលា ឆ្នាំ២០១១

| លរ | អង្គភាពបង្ក្រាប | សរុបរួម | | | ដឹកជញ្ជូន ជួញដូរ | | | ផលិត | | | ដាំដុះ ចម្រាញ់ប្រេងរុក្ខ. | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ចំនួនដីកា | នាក់ | ស្រី |
| 1 | មន្ទីរប្រឆាំង គ្រ.ញ | **5** | **13** | **2** | 4 | 11 | 1 | 1 | 2 | 1 | | | | | | | | | |
| 2 | គយ និង រដ្ឋាករ | **1** | **2** | **0** | 1 | 2 | 0 | | | | | | | | | | | | |
| 3 | ន.ប ភ្នំពេញ | **14** | **33** | **5** | 14 | 32 | 5 | | | | | | | | | | 1 | 1 | 0 |
| 4 | ន.ប កំពង់ចាម | **6** | **15** | **6** | 5 | 8 | 3 | | | | | | | 1 | 3 | 2 | 6 | 4 | 1 |
| | ន.ប ព្រះសីហនុ | **2** | **2** | **0** | 2 | 2 | 0 | | | | | | | | | | | | |
| | ន.ប ស្ទឹងត្រែង | **5** | **10** | **1** | 4 | 7 | 1 | | | | | | | 1 | 2 | 0 | 1 | 1 | 0 |
| | ន.ប ព្រះវិហារ | **1** | **3** | **1** | 1 | 3 | 1 | | | | | | | | | | | | |
| | ន.ប រតនគិរី | **1** | **1** | **0** | 1 | 1 | 0 | | | | | | | | | | | | |
| | ន.ប បាត់ដំបង | **2** | **2** | **2** | 2 | 2 | 2 | | | | | | | | | | | | |
| | ន.ប បន្ទាយមានជ័យ | **3** | **6** | **1** | 3 | 5 | 1 | | | | | | | | | | 1 | 1 | 0 |
| | ពោធិ៍សាត់ | **1** | **3** | **0** | 1 | 3 | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ន.ប កំពង់ធំ | **2** | **5** | **0** | 1 | 1 | 0 | | | | | | | 1 | 4 | 0 | | | |
| | ន.ប ក្រចេះ | **1** | **3** | **0** | | | | | | | | | | 1 | 3 | 0 | | | |
| | ន.ប ប៉ៃលិន | **2** | **4** | **2** | 2 | 3 | 2 | | | | | | | | | | 1 | 1 | 0 |
| | **សរុប** | **46** | **102** | **20** | **41** | 80 | 16 | **1** | 2 | 1 | | | | **4** | 12 | 2 | **10** | 8 | 1 |

## *វត្ថុតាងគ្រឿងញៀន ចាប់យក ប្រចាំខែ តុលា ឆ្នាំ២០១១ (រាយតាមអង្គភាពប្រតិបត្តិការ)*

| លរ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ***WY*** (គ្រាប់) | ***ICE*** (ក្រាម) | ***Heroine*** (ក្រាម) | ដើមកញ្ឆា ម² | កញ្ឆាក្រៀម (ក្រាម) | ***Ecstasy*** (គ្រាប់) | ***Pseudo-Ephedrine*** | កូកាអ៊ីន (ក្រាម) | ប្រេងម្រះព្រៅភ្នំ |
| *1* | មន្ទីរប្រឆាំងគ្រឿងញៀន | | *350,4* | *17,2* | | | | | | |
| *2* | *គយ និង រដ្ឋាករ* | | | | | | *1.045,5 g*<br>*5.227 គ្រាប់* | | | |
| *3* | ន.ប ភ្នំពេញ | *20* | *27,8* | *2,87* | | | *0,30 g* | | | |
| *4* | ន.ប កំពង់ចាម | *20* | *51,62* | | | | | | | |
| *5* | ន.ប ព្រះសីហនុ | | *2,21* | | | | | | | |
| *6* | ន.ប ស្ទឹងត្រែង | *438* | *4,5* | | | | | | | |
| *7* | ន.ប ព្រះវិហារ | | *11* | | | *130* | | | | |
| *8* | ន.ប រតនគីរី | *72* | | | | | | | | |
| *9* | ន.ប បាត់ដំបង | *1.976* | | | | | | | | |
| *10* | ន.ប បន្ទាយមានជ័យ | *330* | *1,9* | | | | | | | |
| *11* | ន.ប ពោធិ៍សាត់ | | *55,5* | | | | | | | |
| *12* | ន.ប កំពង់ធំ | | *18,7* | | | | | | | |
| *13* | ន.ប ក្រចេះ | | *0,01* | | | | | | | |
| *14* | ន.ប ប៉ៃនលិន | *23* | | | | | | | | |
| | សរុប | ***2.879*** | ***523,64*** | ***20,07*** | | ***130*** | ***1.045,8***<br>***5227*** *គ្រាប់* | | | |

## ទ្រព្យសម្បត្តិ និងវត្ថុតាងផ្សេងៗ ពាក់ពន្ធ័នទល្មើសគ្រឿងញៀន

-មន្ទីរប្រឆាំង គ្រ.ញ — ម្សៅមេតំហ្វេតាមីន ៦៥៤,៦ ក្រាម, ម្សៅពណ៌ស សង្ស័យគ្រឿងញៀន ១.២៩៤,៧ ក្រាម, សារជាតុគីមីរាវ ៣៤០,៦ ក្រាម, ជញ្ជីង ៥, ពុម្ព ៩, ឧបករណ៍គ្រីបពុម្ព ១, អាវុធខ្លី ១, ប្រាក់៤៥៦.១០០ រៀល, ៥.៩៥១ ដុល្លារអាមេរិក, ៦.៥០០.០០០ ដុង, រថយន្ត ១, ម៉ូតូ ៣ និងឧបករណ៍វេចខ្ចប់ប្រើប្រាស់មួយចំនួន ។

-គយ-រដ្ឋាករ — Mouse Computer ១០ និង Speaker ២ សម្រាប់, លិខិតឆ្លងដែន ២ ក្បាល ។

-ន.ប ភ្នំពេញ — ជញ្ជីង ៣, ម៉ូតូ ២, Lap Top ១, ប្រាក់ ១៩១.០០០ រៀល, ១៨៦ ដុល្លារសហរដ្ឋអាមេរិក, ឧបករណ៍ប្រើប្រាស់ និងវេចខ្ចប់មួយចំនួន ។

-ន.ប កំពង់ចាម — ជញ្ជីង ២, ឧបករណ៍ប្រើប្រាស់មួយចំនួន

-ន.ប ព្រះសីហនុ — កេតាមីន ២,៦៣ ក្រាម, ម៉ូតូ ១

-ន.ប ស្ទឹងត្រែង — រថយន្ត ១, ប្រាក់ ៨.០០០ ដុល្លារអាមេរិក, ឧបករណ៍វេចខ្ចប់ និងប្រើប្រាស់មួយចំនួន

-ន.ប ព្រះវិហារ — រថយន្ត ១, ឧបករណ៍វេចខ្ចប់ និងប្រើប្រាស់មួយចំនួន

-ន.ប រតនគីរី — ម៉ូតូ ១

-ន.ប បាត់ដំបង — WY ½

-ន.ប ពោធិ៍សាត់ — ម៉ូតូ ១, ប្រាក់ ៦១២ ដុល្លារអាមេរិក, ឧបករណ៍វេចខ្ចប់ និងប្រើប្រាស់មួយចំនួន

-ន.ប កំពង់ធំ — ឧបករណ៍ប្រើប្រាស់មួយចំនួន

-ន.ប ក្រចេះ — ឧបករណ៍ប្រើប្រាស់មួយចំនួន